ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៥ ណណ

# បទបញ្ជា

## ស្តីពី

## ការអនុវត្តន៍ព្រះរាជក្រឹត្យ និងអនុក្រឹត្យ ផ្ទេរ និងសមាហរណកម្ម ការងាររបស់ស្ថាប័នរដ្ឋមួយចំនួន

ដើម្បីអនុវត្តតាមព្រះរាជក្រឹត្យ និងអនុក្រឹត្យ ជាការប្រញាប់នោះ រាជរដ្ឋាភិបាល ដាក់បទបញ្ជាឲ្យរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ រដ្ឋមន្ត្រី ក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រៀបចំបែបបទ និងនីតិវិធីនានាក្នុងការផ្ទេរ និងសមាហរណកម្មរបស់ស្ថាប័នរដ្ឋមួយចំនួន ដូចមានចែងខាងក្រោម ៖

១- គណៈកម្មាធិការជាតិអេស្កាប់ ត្រូវបានផ្ទេរ និងសមាហរណកម្មការងារ និងធនធានសម្ព័ន្ធទាំងឡាយ រួមមាន ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ចលនទ្រព្យ អចលនទ្រព្យ ។ល។ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣

២- គណៈកម្មាធិការជាតិជំរុញចលនា «ភូមិមួយ ផលិតផលមួយ» ត្រូវបានផ្ទេរ និងធ្វើសមាហរណកម្មការងារឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៥៩ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣

៣- គណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ ត្រូវបានផ្ទេរ និងសមាហរណកម្មការងារ និងធនធានសម្ព័ន្ធ ទាំងឡាយ រួមមាន ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ចលនទ្រព្យ អចលនទ្រព្យ ។ល។ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងផែនការ ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦៤ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣

៤- អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា ត្រូវបានផ្ទេរ និងសមាហរណកម្មការងារ និងរចនាសម្ព័ន្ធទាំងឡាយ រួមមាន ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ចលនទ្រព្យ អចលនទ្រព្យ ។ល។ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រង របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦០ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣

៥- រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវបានផ្ទេរ និងសមាហរណកម្មការងារ និងរចនា-សម្ព័ន្ធទាំងឡាយ រួមមាន ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ចលនទ្រព្យ អចលនទ្រព្យ ។ល។ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ ដូចមានចែងក្នុងព្រះរាជ-ក្រឹត្យលេខ នស/រកត/១០១៣/១០៥៨ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣

៦- គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ត្រូវបានផ្ទេរឱ្យស្ថិតនៅក្រោម ការទទួលខុសត្រូវរបស់ក្រសួងយុត្តិធម៌ ដូចមានចែងក្នុងអនុក្រឹត្យលេខ ១០០៧ អនក្រ តត ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣

៧- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានផ្ទេរកញ្ចប់ថវិកា សម្រាប់ការពារជន ក្រីក្រ ឱ្យស្ថិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌ ដូចមានចែងក្នុងអនុក្រឹត្យលេខ ១០០៨ អនក្រ.តត ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣

៨- សាលាភូមិន្ទរដ្ឋបាល ត្រូវបានផ្ទេរ និងសមាហរណកម្មការងារ និងរចនាសម្ព័ន្ធ ទាំងឡាយ រួមមាន ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ចលនទ្រព្យ អចលនទ្រព្យ ។ល។ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមុខងារសាធារណៈ ដូចមានចែងក្នុង ព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦២ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣

៩- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ត្រូវបានផ្ទេរ និងសមាហរណកម្ម ការងារ និងរចនាសម្ព័ន្ធទាំងឡាយ រួមមាន ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ចលន ទ្រព្យ អចលនទ្រព្យ ។ល។ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦១ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣

១០- ក្រុមប្រឹក្សាកីឡាកម្ពុជា ត្រូវបានផ្ទេរ និងសមាហរណកម្មការងារ និងរចនាសម្ព័ន្ធ ទាំងឡាយ រួមមាន ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ចលនទ្រព្យ អចលនទ្រព្យ ។ល។ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដូចមានចែងក្នុង ព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៥៧ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣

១១- គណៈកម្មការអភិរក្ស និងអភិវឌ្ឍតំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ ផ្ទេរឱ្យស្ថិត នៅក្រោមការទទួលខុសត្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមាន ចែងក្នុងអនុក្រឹត្យលេខ ១០០៦ អនក្រ.តត ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១៣ ។

ទទួលបានបទបញ្ជានេះ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តបទបញ្ជាខាងលើនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ៧ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ